ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៥៣ ព.ណ.ឆ.ស.ជ ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១១ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានដើមកំណើតទំនិញ
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ _ គោលបំណង**

ប្រកាសនេះកំណត់អំពីនីតិវិធីនៃការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ក្រោមច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ក្នុងគោលបំណងកំណត់ថាសកម្មភាពណាមួយជាប់ពាក់ព័ន្ធនឹងការក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានអត្រាពន្ធអនុគ្រោះនៅប្រទេសនាំចូល ឬផលប្រយោជន៍នានា ឬដើម្បីគេចវេះពីវិធានការប្រឆាំងការលក់បង្ខូចថ្លៃ វិធានការប៉ះប៉ូវ និងវិធានការការពារ។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ប្រការ២ ._ វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការស៊ើបអង្កេតលើ ផលិតករនិង/ឬអ្នកនាំចេញក្នុងករណីមានការសង្ស័យថាមានជាប់ពាក់ព័ន្ធការក្លែងបន្លំដើមកំណើតទំនិញក្រោមច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ដែលត្រូវអនុវត្តដោយមន្ត្រីស៊ើបអង្កេតដែលជ្រើសរើសចេញពីអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី២
## នីតិវិធីនៃការចុះស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេត

**ប្រការ៣ ._ សិទ្ធិ និងកាតព្វកិច្ច**

មន្ត្រីស៊ើបអង្កេតត្រូវអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនស្របតាមនីតិវិធីដែលមានចែងក្នុងប្រកាសនេះ ក្នុងការចុះពិនិត្យ និងស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីវិធានដើមកំណើតទំនិញ។

នៅពេលដែលអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន មន្ត្រីស៊ើបអង្កេតត្រូវ៖

- បញ្ជាក់ពីឈ្មោះ តួនាទី និងអង្គភាពដែលខ្លួនបម្រើការ
- បង្ហាញដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតអំពីគោលបំណង នៃការអនុវត្តនេះ។

**ប្រការ៤ ._ កិច្ចសហការ**

មន្ត្រីស៊ើបអង្កេតមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ស្របតាមមាត្រា២៤ និងមាត្រា២៧ នៃច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ដើម្បីចូលរួមបង្ក្រាបបទល្មើសក្លែងបន្លំដើមកំណើតទំនិញនាំចេញ។

**ប្រការ៥ ._ នីតិវិធីនៃការចុះស៊ើបអង្កេត**

មន្ត្រីស៊ើបអង្កេតអាចចូលទៅកាន់អាជីវកម្មដ្ឋាន ឬទីតាំងផលិតណាមួយក្នុងម៉ោងធ្វើធុរកិច្ចធម្មតា ដើម្បីចុះពិនិត្យ និងស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីវិធានដើមកំណើតទំនិញ។

ក្នុងអំឡុងពេលចុះបំពេញការងារ មន្ត្រីស៊ើបអង្កេតត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ធ្វើការប្រជុំជាមួយម្ចាស់ឬតំណាងស្របច្បាប់នៃអាជីវកម្មដ្ឋាន ឬទីតាំងផលិត ដើម្បីបង្ហាញពីសមាសភាពមន្ត្រីចូលរួម បញ្ជាក់ពីគោលបំណងនិងសកម្មភាពការងារដែលត្រូវអនុវត្ត និងពីការប្រមូលព័ត៌មានពាក់ព័ន្ធ
- ធ្វើការកត់ត្រាឱ្យបានលម្អិត និងច្បាស់លាស់នូវព័ត៌មាន ដើម្បីបំពេញកំណត់ហេតុយកសំណាក និងថតភស្តុតាងដែលបានពិនិត្យឃើញនៅតាមទីកន្លែង ឬគោលដៅស៊ើបអង្កេត
- ធ្វើការប្រជុំបូកសរុបលទ្ធផលត្រួតពិនិត្យ ជាមួយម្ចាស់ ឬតំណាងស្របច្បាប់នៃអាជីវកម្មដ្ឋាន ឬទីតាំងផលិត ដោយត្រូវធ្វើកំណត់ហេតុបញ្ជាក់ពីបញ្ហាដែលបានពិនិត្យឃើញ ឬសេចក្តីបង្គាប់ឱ្យមានការកែតម្រូវជាកំហិត
- ធ្វើការផ្ទៀងផ្ទាត់ខ្លឹមសារកំណត់ហេតុ ដោយមានការចូលរួមទទួលដឹងឮពីម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់អាជីវកម្មដ្ឋាន ឬទីតាំងផលិត តាមរយៈការអាន ការបកប្រែ ការផ្តិតស្នាមមេដៃលើកំណត់ហេតុ និងការផ្តល់ច្បាប់ចម្លងទៅគ្រប់តំណាងចូលរួម
- អនុវត្តវិធានការដើម្បីរក្សា ឬការពារឯកសារ ទំនិញ ដែលមន្ត្រីស៊ើបអង្កេតកំណត់ថាមានពាក់ព័ន្ធនឹងការស៊ើបអង្កេត។

**ប្រការ៦ ._ ការអនុវត្តលើបទល្មើសក្លែងបន្លំជាក់ស្តែងដែលរកឃើញក្នុងពេលចុះស៊ើបអង្កេត**

ក្នុងករណីពេលចុះអនុវត្តការស៊ើបអង្កេតរកឃើញបទល្មើសក្លែងបន្លំជាក់ស្តែងណាមួយ មន្ត្រីស៊ើបអង្កេតត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

- ប្រមូលវត្ថុតាង ឬសំណាកពាក់ព័ន្ធនឹងបទល្មើសក្លែងបន្លំ និងធ្វើកំណត់ហេតុដោយឡែកអំពីបទល្មើសជាក់ស្តែងដែលបានរកឃើញ
- ចាត់វិធានការផ្អាកជាបណ្តោះអាសន្ននៃការអនុញ្ញាតនាំចេញ។

**ប្រការ៧.-** **ប្រតិបត្តិការក្រោយការចុះស៊ើបអង្កេត**

ក្រោយការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការស៊ើបអង្កេត ជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មពិនិត្យក្នុងរយៈពេលមិនលើសពី ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះបំពេញការងារ។

**ប្រការ៨.-** **វិធានការបន្តក្រោយការចុះស៊ើបអង្កេត**

ក្រោយការពិនិត្យ និងសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រីស៊ើបអង្កេតត្រូវបន្តការអនុវត្តវិធានការបន្ទាន់ទៅតាមសេចក្ដីសម្រេចរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម។

**ប្រការ៩.-** **ការរក្សាការសម្ងាត់នៃព័ត៌មាន**

មន្ត្រីចុះស៊ើបអង្កេត ត្រូវមានការទទួលខុសត្រូវ ក្នុងការរក្សាការសម្ងាត់នៃព័ត៌មានឯកសារកំណត់ត្រា រូបភាព និងលទ្ធផលវិភាគសំណាក ដែលប្រមូលបានក្នុងពេលធ្វើការស៊ើបអង្កេត លើកលែងតែមានការអនុញ្ញាតដោយច្បាប់ ឬការបង្គាប់របស់តុលាការ។

## ជំពូកទី៣
## សិទ្ធិ និងភារកិច្ចរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត

**ប្រការ១០.-** **សិទ្ធិក្នុងការការពារខ្លួន**

បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធទទួលបានសិទ្ធិការពារខ្លួនស្របច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១១.-** **ភារកិច្ចសហការ និងការទទួលខុសត្រូវ**

បុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលពាក់ព័ន្ធត្រូវសហការជាមួយនឹងមន្ត្រីស៊ើបអង្កេត ដើម្បីអនុវត្តការស៊ើបអង្កេតតាមនីតិវិធី ដូចមានចែងក្នុងប្រកាសនេះ ដោយសុចរិតភាព ភាពស្មោះត្រង់ និងតម្លាភាព។

បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ត្រូវទទួលខុសត្រូវស្របតាមក្រមព្រហ្មទណ្ឌ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១២.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាននាំចេញ នាំចូល ប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញក្នុងតំបន់សេដ្ឋកិច្ចពិសេស ប្រធានគ្រប់នាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិត្រពាំងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh